**EMBASSY OF JAPAN IN CAMBODIA**

# PRESS RELEASE

No. 12PR-25/EoJ 17 February 2026

## Japan Provides US$316,484 for Enhancing a Community-Based Surgical Care System in Kratie Province

The Government of Japan will provide US$316,484 for the recipient organization under the framework, *the Grant Assistance for Japanese NGO Projects*. The Grant Contract was signed today between H.E. Mr. UENO Atsushi, Ambassador Extraordinary and Plenipotentiary of Japan to the Kingdom of Cambodia, and the representative of the recipient, to carry out the following project:

‘Project for Strengthening and Expanding Surgical Care in Northeastern Cambodia’
(US$316,484)
Recipient: Foundation for International Development/Relief (FIDR)

This project seeks to enhance a community-based surgical care system in Kratie Province, enabling patients to receive timely and appropriate surgical treatment. The project’s key components include strengthening the skills of medical personnel, fostering collaboration among local healthcare facilities, and installing surgical equipment at Kratie Provincial Hospital.

*The Grant Assistance for Japanese NGO Projects* started in Cambodia in 2002 to support activities by Japanese NGOs to help Cambodia's reconstruction and development efforts at the grassroots level. Since 2002, the Government of Japan has provided over US$60 million for over 170 projects, mainly in the field of primary education, health, agriculture and mine clearance in Cambodia.

---

*Embassy of Japan in Cambodia*
*Tel: 023-217-161*
*Email:* eco.jpn@pp.mofa.go.jp
*Website:* *http://www.kh.emb-japan.go.jp*

**ស្ថានទូតជប៉ុន**

**ប្រចាំប្រទេសកម្ពុជា**

**សេចក្តីប្រកាសពត៌មាន**

លេខ. 12PR-25/EoJ ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២៦

**ជប៉ុនផ្តល់ថវិកា ៣១៦,៤៨៤ ដុល្លារអាមេរិក**

**សម្រាប់ការលើកកម្ពស់ប្រព័ន្ធថែទាំវះកាត់តាមសហគមន៍ នៅក្នុងខេត្តក្រចេះ**

រដ្ឋាភិបាលជប៉ុន នឹងផ្តល់ថវិកាសរុបចំនួន **៣១៦,៤៨៤ ដុល្លារអាមេរិក** ដល់អង្គភាពទទួលជំនួយចំនួនមួយក្រោមគ្រោងការណ៍ជំនួយឥតសំណងសម្រាប់គម្រោងអង្គការក្រៅរដ្ឋាភិបាលជប៉ុន។ កិច្ចសន្យាផ្តល់ជំនួយ ត្រូវបានចុះហត្ថលេខានៅថ្ងៃនេះ ដោយ **ឯកឧត្តម អ៊ូអិណុ អាត់ស៊ូស៊ី** ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាពរបស់ប្រទេសជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា និង អ្នកតំណាងស្ថាប័នទទួលជំនួយសម្រាប់អនុវត្តគម្រោងខាងក្រោម៖

**"គម្រោងពង្រឹង និងពង្រីកការថែទាំវះកាត់ នៅក្នុងតំបន់ភូមិភាគឦសាន្ត នៃប្រទេសកម្ពុជា" (ថវិកាចំនួន ៣១៦,៤៨៤ ដុល្លារអាមេរិក)**

**ស្ថាប័នទទួលជំនួយ៖ អង្គការមូលនិធិសម្រាប់ការអភិវឌ្ឍន៍ និងជំនួយសង្គ្រោះអន្តរជាតិ (FIDR)**

គម្រោងនេះមានគោលបំណងលើកកម្ពស់ប្រព័ន្ធថែទាំវះកាត់តាមសហគមន៍ នៅក្នុងខេត្តក្រចេះ ដែលអាចឱ្យអ្នកជំងឺទទួលបានការព្យាបាលវះកាត់ទាន់ពេលវេលា និងសមស្រប។ ចំនុចសំខាន់ៗរបស់គម្រោងរួមមានការពង្រឹងជំនាញរបស់បុគ្គលិកពេទ្យ ការជំរុញកិច្ចសហប្រតិបត្តិការក្នុងចំណោមកន្លែងថែទាំសុខភាពក្នុងស្រុក និងការតម្លើងឧបករណ៍វះកាត់នៅមន្ទីរពេទ្យខេត្តក្រចេះ។

ជំនួយឥតសំណងសម្រាប់គម្រោងអង្គការក្រៅរដ្ឋាភិបាលជប៉ុន បានចាប់ផ្តើមនៅប្រទេសកម្ពុជាតាំងពីឆ្នាំ២០០២ ដើម្បីគាំទ្រដល់សកម្មភាពរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុន ក្នុងកិច្ចខិតខំប្រឹងប្រែង ដើម្បីជួយដល់ការអភិវឌ្ឍ និងស្តារបនាប្រទេសកម្ពុជាឡើងវិញនៅតាមកម្រិតមូលដ្ឋាន។ ចាប់តាំងពីឆ្នាំ២០០២មក រដ្ឋាភិបាល

ជប៉ុនបានផ្តល់ថវិកាជាង ៦០លានដុល្លារអាមេរិក ដល់គម្រោងចំនួន ១៧០ ដែលផ្តោតសំខាន់ទៅលើវិស័យអប់រំនៅកម្រិតបឋមសិក្សា វិស័យសុខាភិបាល វិស័យកសិកម្ម និងសកម្មភាពបោសសម្អាតមីនក្នុងប្រទេសកម្ពុជា។

---


ស្ថានទូតជប៉ុនប្រចាំប្រទេសកម្ពុជា

ទូរសព្ទ៖ ០២៣-២១៧-១៦១

អ៊ីម៉ែល៖ *eco.jpn@pp.mofa.go.jp*

គេហទំព័រ៖ *http://www.kh.emb-japan.go.jp*

**សុន្ទរកថារបស់ ឯកឧត្តម អ៊ូអ៊ិណុ អាត់ស៊ូស៊ី**
**ឯកអគ្គរាជទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា**
**ថ្លែងក្នុងពិធីចុះហត្ថលេខាលើកិច្ចសន្យា**
**ផ្តល់ជំនួយឥតសំណងសម្រាប់គម្រោងអង្គការក្រៅរដ្ឋាភិបាលជប៉ុន**
**ថ្ងៃអង្គារ ទី១៧ ខែកុម្ភៈ ឆ្នាំ២០២៦**

**គម្រោង៖ «គម្រោងពង្រឹង និងពង្រីកការថែទាំវះកាត់ នៅក្នុងតំបន់ភូមិភាគឦសាន្ត នៃប្រទេសកម្ពុជា»**
**ស្ថាប័នអនុវត្ត៖ អង្គការមូលនិធិសម្រាប់ការអភិវឌ្ឍន៍ និងជំនួយសង្គ្រោះអន្តរជាតិ( FIDR)**

- សូមគោរពលោក សាអេគិ ខាហ្សាតុ នាយកប្រចាំប្រទេសកម្ពុជា នៃអង្គការមូលនិធិសម្រាប់ការអភិវឌ្ឍន៍ និងជំនួយសង្គ្រោះអន្តរជាតិ (FIDR )
- លោក លោកស្រី ភ្ញៀវកិត្តិយស ទាំងអស់ជាទីមេត្រី។

ថ្ងៃនេះ ខ្ញុំមានសេចក្តីសោមនស្សរីករាយយ៉ាងក្រៃលែងដែលបានរៀបចំពិធីចុះហត្ថលេខាលើកិច្ចសន្យាផ្តល់ជំនួយឥតសំណងសម្រាប់គម្រោងអង្គការក្រៅរដ្ឋាភិបាលជប៉ុននៃឆ្នាំសារពើពន្ធ២០២៥។

មុននឹងចូលប្រធានបទកម្មវិធីថ្ងៃនេះ អនុញ្ញាតិឲ្យរូបខ្ញុំលើកឡើងពីជម្លោះព្រំដែនរវាងកម្ពុជា ថៃ បន្តិច។ រដ្ឋាភិបាលជប៉ុន និងរូបខ្ញុំផ្ទាល់ ស្វាគមន៍ការសម្រេចបាននូវកិច្ចព្រមព្រៀងបទឈប់បាញ់លើកទីពីររវាងកម្ពុជា និងថៃ និងការវិលត្រឡប់របស់ទាហានកម្ពុជាចំនួន១៨រូប កាលពីចុងឆ្នាំមុន ។ រដ្ឋាភិបាលជប៉ុនសន្យាថានឹងបន្តកិច្ចខិតខំប្រឹងប្រែងដើម្បីជំរុញការកាត់បន្ថយភាពតានតឹង ដោយសហការជាមួយប្រទេសពាក់ព័ន្ធ ព្រមទាំងផ្តល់ការគាំទ្រនានាផងដែរ ។

ជំនួយឥតសំណងសម្រាប់គម្រោងអង្គការក្រៅរដ្ឋាភិបាលជប៉ុន ដែលហៅថា “អ៊ិនរ៉េន” បានចាប់ផ្តើមតាំងពីឆ្នាំ២០០២ ដើម្បីគាំទ្រដល់អង្គការក្រៅរដ្ឋាភិបាលជប៉ុន ក្នុងការអនុវត្តគម្រោងអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមរបស់ពួកគេនៅក្នុងប្រទេស ឬតំបន់កំពុងអភិវឌ្ឍ។ ក្នុងរយៈពេល២០ឆ្នាំចុងក្រោយនេះ ស្ថានទូតជប៉ុនបានផ្តល់ជំនួយជាង ១៦០គម្រោង នៅក្នុងប្រទេសកម្ពុជាតាមរយៈកម្មវិធីនេះ ហើយគម្រោងទាំងនេះបានចូលរួមចំណែកដោយផ្ទាល់ក្នុងការកែលម្អគុណភាពជីវិតរបស់ប្រជាជនកម្ពុជា។

ខ្ញុំសូមជម្រាបជូនដោយសង្ខេបអំពី ដែលយើងបានចុះហត្ថលេខានាថ្ងៃនេះ៖

រដ្ឋាភិបាលជប៉ុននឹងផ្តល់ថវិកា ប្រមាណ ៣២ម៉ឺនដុល្លារអាមេរិកដល់អង្គការ FIDR សម្រាប់ អនុវត្តគម្រោងរបស់ខ្លួននៅក្នុងខេត្តក្រចេះ។

អង្គការ FIDR បានចាប់ផ្តើមកិច្ចសហប្រតិបត្តិការផ្នែកវេជ្ជសាស្ត្រនៅក្នុងប្រទេសកម្ពុជាក្នុងឆ្នាំ 1996 ក្នុងគោលបំណងបង្កើតប្រព័ន្ធវេជ្ជសាស្រ្តវះកាត់កុមារ។ ហើយចាប់តាំងពីឆ្នាំ 2017 អង្គការនេះបាននិងកំពុងខិតខំប្រឹងប្រែងពង្រឹង និងពង្រីកការវះកាត់កុមារនៅក្នុងខេត្តក្រចេះ ដែលជាខេត្តដ៏សំខាន់មួយនៅភូមិភាគឦសាន។ យើងសូមសម្តែងនូវការគោរពដ៏ជ្រាលជ្រៅរបស់ជាថ្មីម្តងទៀតចំពោះសមិទ្ធផលដ៏ធំធេងជាច្រើនឆ្នាំរបស់ពួកគេ។

សម្រាប់គម្រោងដែលបានចុះហត្ថលេខានាថ្ងៃនេះ អង្គការ FIDR នឹងពង្រឹងប្រព័ន្ធវេជ្ជសាស្ត្រតាមសហគមន៍ ដោយយកខេត្តក្រចេះជាគោល ដើម្បីឲ្យប្រជាជនក្នុងតំបន់ទទួលបានការថែទាំវះកាត់សមស្រប។ លើសពីនេះទៅទៀត

គម្រោងនេះ លើកកំពស់ជំនាញរោគវិនិច្ឆ័យអ្នកជំងឺរះកាត់របស់គ្រូពេទ្យនៅមន្ទីរពេទ្យបង្អែកស្រុក និងសមត្ថភាពឆ្លើយតបរបស់បុគ្គលិកស្ថាប័នវេជ្ជសាស្ត្រ រួមមានមណ្ឌលសុខភាពជាដើម ព្រមទាំងពង្រឹងកិច្ចសហប្រតិបត្តិការជាមួយស្ថាប័នវេជ្ជសាស្ត្រកម្រិតខ្ពស់ រួមមានមន្ទីរពេទ្យបង្អែកខេត្តក្រចេះដើម្បីជំរុញការបង្កើតប្រព័ន្ធពិគ្រោះជំងឺឱ្យបានឆាប់រហ័ស។

ខ្ញុំមានសេចក្តីសោមនស្សរីករាយដោយសង្កេតឃើញថានាពេលថ្មីៗនេះ ប្រទេសកម្ពុជាបាននិងកំពុងអភិវឌ្ឍយ៉ាងឆាប់រហ័ស។ ទោះយ៉ាងណា ខ្ញុំក៏ទទួលស្គាល់ថានៅតែមានបញ្ហាប្រឈមមួយចំនួនដែលត្រូវដោះស្រាយ ដើម្បីកែលម្អគុណភាពជីវិតរបស់ប្រជាជន ដែលរួមមាន ការបោសសម្អាតមីន និងយុទ្ធភណ្ឌមិនទាន់ផ្ទុះ ក៏ដូចជាការកាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍសង្គម ដូចជា សុខភាព ការអប់រំ និងបរិស្ថានផងដែរ។ រដ្ឋាភិបាលជប៉ុន នឹងបន្តសហការជាមួយអង្គការក្រៅរដ្ឋាភិបាលអន្តរជាតិរបស់ជប៉ុន ក្នុងការដោះស្រាយបញ្ហានានា។

ជាទីបញ្ចប់ ខ្ញុំសង្ឃឹមថាគម្រោងដែលបានចុះហត្ថលេខានាថ្ងៃនេះដំណើរការទៅដោយរលូន និងទទួលបានភាពជោគជ័យនាពេលអនាគត។ ហើយខ្ញុំក៏សូមជូនពរ លោក លោកស្រី ដែលមានវត្តមាននៅទីនេះ សូមមានសុខភាពល្អ សុភមង្គល និង សូមឱ្យមិត្តភាពជប៉ុន-កម្ពុជាកាន់តែរីកចម្រើន។

សូមអរគុណ។